ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ៧៤៦ លធណ . ធទឧ

## សេចក្តីជូនដំណឹង
## ស្តីពី ស្ថានភាពច្រាំងទន្លេ

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា : ចាប់តាំងពីពាក់កណ្តាលខែសីហា ឆ្នាំ 2011 មកដល់ពេលបច្ចុប្បន្ន ទឹកទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ បានហក់ឡើងយ៉ាងខ្ពស់។ ទឹក បានហូរចេញពីទន្លេទាំងនេះទៅកាន់ព្រៃក បឹងបួរ តំបន់ទំនាបលិចទឹកនានា... បង្កឱ្យមានជាទឹកជំនន់យ៉ាងធ្ងន់ធ្ងរ ពិសេសនៅតាមបណ្តារាជធានី-ខេត្ត ដែលមានភូមិសាស្ត្រជាប់នឹងដងទន្លេ ។ ស្ថានភាពកំពស់ទឹកទន្លេ និងស្ថានភាពទឹកជំនន់ដូចបានជម្រាបជូនមកនេះ បានធ្វើឱ្យច្រាំងទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ មានសភាពសើមជាប់ជាប្រចាំ បាត់បង់អស់មួយផ្នែកនូវលំនឹង ។

បច្ចុប្បន្នទឹកទន្លេមេគង្គ ទន្លេបាសាក់ និងទន្លេសាបចាប់ផ្តើមស្រក ហើយនឹងស្រកចុះកាន់តែលឿនពីមួយថ្ងៃទៅមួយថ្ងៃ ។ នៅពេលដែលទឹកចាប់ផ្តើមស្រក ច្រាំងទន្លេនានា ប្រឈមនឹងបាតុភូតជលសាស្ត្រធំពីរ គឺ :

1- ទឹកដែលបានលិចតំបន់នានា បានប្រមូលផ្តុំហូរចូលទន្លេវិញ ។ បាតុភូតនេះ គឺហាក់ដូចជាទាញច្រាំងទន្លេឱ្យបាក់ស្រុត ។

2- ទឹកដែលហូរស្រកចុះ មានធារទឹកខ្លាំង ក៏ជាកត្តាស្រូបទាញច្រាំងទន្លេផងដែរ ។

បាតុភូតទាំងពីរខាងលើ រួមផ្សំនឹងស្ថានភាពច្រាំងទន្លេបច្ចុប្បន្នដែលមានសភាពសើម ទន់ ដោយការត្រាំទឹកជំនន់ជាយូរមកហើយនោះ អាចធ្វើឱ្យច្រាំងទន្លេប្រឈមនឹងការបាក់ស្រុតចុះក្នុងកម្រិតខ្ពស់ ជាងពេលទឹកឡើង ។

ដោយយោងលើស្ថានភាព និងបាតុភូត ដូចបានជម្រាបជូនខាងលើ ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងបងប្អូនប្រជាពលរដ្ឋដែលមានលំនៅដ្ឋានតាមដងទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ សូមបង្កើនការយកចិត្តទុកដាក់ខ្ពស់បំផុត ដើម្បីចៀសវាងនូវរាល់គ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែតុលា ឆ្នាំ ២០១១

រដ្ឋមន្ត្រី

លឹម គានហោ